# របាយការណ៍ប្រចាំត្រីមាសទី៤
# ឆ្នាំ២០២៤

០១ តុលា - ៣១ ធ្នូ ២០២៤

## អ អិម អេ (ខេមបូឌា) ម.ក

R M A (CAMBODIA) PLC.

ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក
ទីស្នាក់ការចុះបញ្ជីផ្ទះលេខ ២៧ ផ្លូវលេខ១៣៤ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទទំនាក់ទំនង: +៨៥៥ (0) ២៣-៨៨៨-០០០, ទូរស័ព្ទចល័ត: +៨៥៥ (0) ២៣-៨២៦-៧៥២
www.cambodia.rmagroup.net

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាពាន់រៀល) | ត្រីមាសទ៤ ឆ្នាំ២០២៤ | ២០២៣ | ២០២២ |
|---|---|---|---|
| ទ្រព្យសកម្មសរុប | ៨៧៩.៥៤១.៦៥៦ | ១.០៩៣.៥១១.៧១០ | ៨៨៩.២៩៥.២៣២ |
| បំណុលសរុប | ៣៥៩.៧៦៣.០០១ | ៥៨៦.៦០៩.៧៤៦ | ៤៥១.៣៩២.៤៣៣ |
| មូលធនក្រុមហ៊ុនសរុប | ៥១៩.៧៧៨.៦៥៥ | ៥០៦.៩០១.៩៦៤ | ៤៣៧.៩០២.៧៩៩ |

| ប្រាក់ចំណេញ/(ខាត) (គិតជាពាន់រៀល) | ត្រីមាសទី៤ ឆ្នាំ២០២៤ | ត្រីមាសទី៤ ឆ្នាំ២០២៣ | ត្រីមាសទី៤ ឆ្នាំ២០២២ |
|---|---|---|---|
| ចំណូលសរុប | ៣៩៦.០៧៣.៤៦៩ | ៣១៥.២៥០.៣៤៦ | ៦៧០.៥១៧.០៩២ |
| ប្រាក់ចំណេញដុល | ៦៨.៦៦៩.១៣០ | ៤៩.៤៩៧.៨២៩ | ១៣១.៥៥៤.៣៤៥ |
| ប្រាក់ចំណេញពីកិច្ចប្រតិបត្តិការ | ២៤.១២២.២១៦ | (៦.៣១៨.៨៤៣) | ៨៤.០១៨.០០២ |
| បន្ទុកហិរញ្ញប្បទាន | ៥.៥៤០.៥៧៦ | ៨.៦២២.៣៥៦ | ៥.២៥៩.៤៨៣ |
| ប្រាក់ចំណេញ/(ខាត)មុនបង់ពន្ធ | ២០.២៧៧.៨២៤ | (១៤.៩៤១.១៩៩) | ៧៨.៧៥៨.៥១៩ |
| ប្រាក់ចំណេញ (ខាត) ក្រោយបង់ពន្ធ | ១៤.១៤៩.៨៤១ | (១៣.០៧៥.៤៥៣) | ៦២.៧៥៨.៤៥០ |
| លទ្ធផលចំណេញលម្អិតក្នុងគ្រា | ៩.៥៤៣.៩៧២ | (១៦.៥០៨.៨៤៩) | ៦៤.២០៨.១០៤ |

| អនុបាតហិរញ្ញវត្ថុ | ត្រីមាសទី៤ ឆ្នាំ២០២៤ | ២០២៣ | ២០២២ |
|---|---|---|---|
| អនុបាតសាធនភាព | ០,៧ | ១,២ | ១,០ |
| អនុបាតចរន្ត (Current Ratio) | ៤,២ | ២,៥ | ២,០ |
| អនុបាតចរន្តលឿន (Quick Ratio) | ១,៨ | ០,៦ | ០,៧ |

| អនុបាតចំណេញភាព | ត្រីមាសទី៤ ឆ្នាំ២០២៤ | ត្រីមាសទី ៤ ឆ្នាំ២០២៣ | ត្រីមាសទី ៤ ឆ្នាំ២០២២ |
|---|---|---|---|
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម | ១,០% | -១,៧% | ៨,៦% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម | ១,៩% | -៣,៥% | ១៧,៧% |
| គម្លាតចំណេញដុល (Gross Profit Margin) | ១៧,៣% | ១៥,៧% | ១៩,៦% |
| គម្លាតចំណេញ (Profit Margin) | ២,៤% | -៥,២% | ៩,៦% |
| អនុបាតលទ្ធភាពបង់ការប្រាក់ | ៤,៤ | (០,៧) | ១៦,០ |

## ក្រាបស្តីអំពីស្ថានភាពហិរញ្ញវត្ថុសង្ខេប










ប្រាក់ចំណូល និង ចំណូលសុទ្ធ (គិតជាពាន់រៀល)
2,500,000,000
2,000,000,000
1,500,000,000
1,000,000,000
500,000,000
-
12.0%
10.0%
8.0%
6.0%
4.0%
2.0%
0.0%
១១,២%
២.២០៣.២៥៣.៤៥៣
១.៨០០.៣៦២.០៩៤
១.៦៣១.០៩៥.៦៩៤
៦,១%
៣,៧%
២០២២
២០២៣
២០២៤
ប្រាក់ចំណូល
ចំណូលសុទ្ធ %

...

# សមាជិកក្រុមប្រឹក្សាភិបាល



លោក Christian Wiedmann | លោក ខន សាំខ | លោក Kevin Whitcraft | លោក Tom Whitcraft | លោក Ith Vichit

លោក Kevin Whitcraft

ប្រធានក្រុមប្រឹក្សាភិបាល

លោក ខន សាំខ

អភិបាលប្រតិបត្តិ

លោក Tom Whitcraft

អភិបាលមិនប្រតិបត្តិ

លោក Christian Wiedmann

អភិបាលមិនប្រតិបត្តិ

លោក Ith Vichit

អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

វិនិយោគិនជាទីគោរព

ក្នុងរបាយការណ៍ប្រចាំត្រីមាសមុនៗ ខ្ញុំបាទបានជម្រាបជូនអំពីរបាយការណ៍សង្ខេបស្តីពីលទ្ធផលប្រតិបត្តិការហិរញ្ញវត្ថុរបស់ ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក (តទៅនេះហៅកាត់ថា "ក្រុមហ៊ុន RMAC") ស្របទៅតាមលក្ខខណ្ឌតម្រូវរបស់និយ័តករមូលបត្រកម្ពុជា (ន.ម.ក)។

ខាងក្រោមនេះជាការឆ្លុះបញ្ចាំងមួយចំនួនអំពីដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២៤។ ក្នុងឆ្នាំ២០២៤ ចំនួននៃការនាំចេញរបស់កម្ពុជាបានបង្ហាញពីកំណើនឡើងវិញយ៉ាងខ្លាំងក្លាចំនួន +២៥% ធៀបនឹងឆ្នាំមុន ដែលធៀបនឹងការធ្លាក់ចុះ -៤% ចន្លោះឆ្នាំ ២០២២ និង ២០២៣។ វាជាសញ្ញាណល្អតាមរយៈការមើលលើចំណាយគ្រួសារ ដែលអាករលើការប្រើប្រាស់ (អាករលើតម្លៃបន្ថែម និងពន្ធគយ) បានកើនឡើងក្នុងឆ្នាំ២០២៤ ចំនួន +៦% បើធៀបទៅហ្នឹងឆ្នាំ២០២៣ ដែលធ្លាក់ចុះ -១៣% ទាបជាងឆ្នាំមុន។ គួឱ្យកត់សម្គាល់ថា ឆមាសទីពីរនៃឆ្នាំ២០២៤ អាករលើការប្រើប្រាស់មានដល់ +៣៣% លើសឆ្នាំកន្លងមក។ វិស័យអចលនទ្រព្យ និងសំណង់ហាក់មិនទាន់ប្រសើរឡើងក្នុងឆ្នាំ២០២៤ ដោយសារការធ្លាក់ចុះនៃប្រតិបត្តិការទិញលក់ និងការផ្គត់ផ្គង់លើសតម្រូវការ។ បច្ចុប្បន្ននេះ វិស័យធនាគារកំពុងខំប្រឹងដោះស្រាយ ជាមួយប្រាក់កម្ចី១៤% ដែលជំពាក់មិនសងតាមកាលកំណត់ ទោះបីជាយ៉ាងណាក៏ដោយ អ្នកវិភាគបានបង្ហាញថាយើងបានឆ្លងផុតកម្រិតខ្ពស់រួចហើយ។

នៅក្នុងលក្ខខណ្ឌនៃការលក់រថយន្ត ទិន្នន័យរបស់ក្រុមហ៊ុនបង្ហាញថាទីផ្សាររថយន្តថ្មីបានកើនឡើងបើធៀបនឹងឆ្នាំ ២០២៣។ ដូចគ្នាទៅនឹងនិន្នាការដែលបានប្រើលើអាករលើការប្រើប្រាស់ ការលក់រថយន្តបានកើនឡើងយ៉ាងខ្លាំងនៅក្នុងឆមាសទីពីរនៃឆ្នាំនេះ។

ចុងត្រីមាសឆ្នាំ២០២៤ RMAC ទទួលបានប្រាក់ចំណូលកើនឡើង +២៥.៦% បើប្រៀបធៀបទៅនឹងត្រីមាសដូចគ្នាក្នុងឆ្នាំ២០២៣។ ក្រុមហ៊ុនបានកត់ត្រាការលក់ខ្ពស់បំផុតប្រចាំឆ្នាំរបស់ខ្លួននៅក្នុងខែធ្នូ។ តារាងតុល្យការបង្ហាញពីស្ថានភាពសមតុល្យសាច់ប្រាក់ដ៏រឹងមាំ ដែលតំណាងឱ្យការកើនឡើងនៃសាច់ប្រាក់ចំនួន +៥៤% បើប្រៀបធៀបទៅនឹងខែធ្នូ ឆ្នាំ២០២៣ ។

ក្រុមការងារ RMAC របស់យើងនៅតែបន្តមានភាពសកម្មយ៉ាងខ្លាំងដើម្បីបង្កើនភាពស្មោះត្រង់ និងទំនុកចិត្តរបស់អតិថិជន។ ត្រីមាសនេះមានការសម្ពោធជាផ្លូវការនៃអគារតាំងបង្ហាញរថយន្តJeep (Stellantis Group) នៅក្នុងផ្សារទំនើប Olympia Mall ។ ផ្នែកគ្រឿងចក្រកសិកម្មពង្រឹងការឈានជំហានរបស់ខ្លួនដោយបានបើកដំណើរការមជ្ឈមណ្ឌលដ៏ឈានមុខមួយក្នុងខេត្តត្បូងឃ្មុំ។ ការវិនិយោគទាំងនេះបានបង្ហាញឱ្យឃើញពីការប្តេជ្ញាចិត្តយូរអង្វែងដែលក្រុមហ៊ុន RMA Group បានធ្វើកន្លងមកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំពិតជាមានមោទនភាពយ៉ាងខ្លាំង ចំពោះក្រុមការងារផ្នែកគ្រឿងចក្រកសិកម្មសម្រាប់កិច្ចខិតខំប្រឹងប្រែងដ៏អស្ចារ្យ ដើម្បីបង្ហាញវត្តមានផ្នែកគ្រឿងចក្រកសិកម្ម របស់យើងនៅតាមបណ្តាខេត្ត ដើម្បីបំពេញសេវាកម្មឱ្យកាន់តែប្រសើរឡើងដល់អតិថិជនផ្នែកកសិកម្មរបស់យើង។ ចំពោះការប្រឹងប្រែងនេះ Jonh Deereបានបង្ហាញតាមរយៈការផ្តល់រង្វាន់ពីរគឺ "JDA Outstanding Dealer Award" និង "A&CS High Performance Dealer Award" ចំពោះកិច្ចខិតខំប្រឹងនេះ។

ខាងផ្នែកទំនួលខុសត្រូវសង្គមសាជីវកម្ម ក្នុងអំឡុងពេលដំណើរកម្សាន្ត Ford Adventure ក្រុមការងារ និងអតិថិជន បានបរិច្ចាកទៅដល់ ៤០០គ្រួសារនៅទីជនបទ។

ក្នុងនាមខ្ញុំបាទតំណាងឱ្យក្រុមប្រឹក្សាភិបាលទាំងអស់ សូមថ្លែងអំណរគុណចំពោះអតិថិជនទាំងអស់នៅក្នុងប្រទេសកម្ពុជា ដែលតែងតែមានភក្តីភាព និងមានការចូលចិត្ត និងតែងតែគាំទ្រដល់ក្រុមហ៊ុនយើងខ្ញុំកន្លងមក។ យើងខ្ញុំសូមជូនពរដល់ប្រជាជនកម្ពុជាទាំងអស់ សូមមានសុខសុវត្ថិភាព និងសុខភាពល្អជានិច្ចនិរន្តន៍។

លោក Kevin Whitcraft
ប្រធានក្រុមប្រឹក្សាភិបាល
កាលបរិច្ឆេទ៖ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៥

មាតិកា


**ព័ត៌មានហិរញ្ញវត្ថុសង្ខេប** ..... 3

**ក្រាបស្ដីអំពីស្ថានភាពហិរញ្ញវត្ថុសង្ខេប** ..... 4

**សមាជិកក្រុមប្រឹក្សាភិបាល** ..... 6

**សេចក្ដីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល** ..... 7

ផ្នែកទី១.- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ ..... 10

ក. ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ ..... 10

ខ. សកម្មភាពអាជីវកម្ម ..... 10

គ. ព្រឹត្តិការណ៍សំខាន់ៗក្នុងរយៈពេលនៃរបាយការណ៍ត្រីមាស ..... 11

ផ្នែកទី២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ..... 12

ក. លទ្ធផលប្រតិបត្តិការធុរកិច្ច និង ព័ត៌មានធុរកិច្ចតាមផ្នែក ..... 12

ខ. រចនាសម្ព័ន្ធប្រាក់ចំណូល ..... 13

ផ្នែកទី៣.- របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករ ..... 14

ផ្នែកទី៤. ការពិភាក្សា និង ការវិភាគរបស់គណៈគ្រប់គ្រង ..... 15

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ..... 15

ខ. កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ ..... 16

គ. ការផ្លាស់ប្ដូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល ..... 16

ឃ. ផលប៉ះពាល់នៃអត្រាប្ដូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ ..... 16

ង. ផលប៉ះពាល់នៃអតិផរណា ..... 16

ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល ..... 16

ឆ. ព្រឹត្តិការណ៍សំខាន់ផ្សេងៗ ..... 16

ហត្ថលេខារបស់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ..... 17

## ផ្នែកទី១.- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ

### ក. ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ

| ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាខ្មែរ | អ អិម អេ (ខេមបូឌា) ម.ក |
|---|---|
| ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាឡាតាំង | RMA (CAMBODIA) PLC |
| លេខកូដស្តង់ដារ | KH2000121A44 |
| អាសយដ្ឋាន | ផ្ទះលេខ ២៧ E1 ផ្លូវ ១៣៤ សង្កាត់មិត្តភាព ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ (០) ២៣ ៨៨៣ ៩៨៨ / ១២ ៨៦៧ ៦៩៧ |
| លេខទូរសារ | +៨៥៥ (០) ២៣ ៩២៦ ៧៥២ |
| គេហទំព័រ | www.cambodia.rmagroup.net |
| អ៊ីម៉ែល | saing.ngorn@rmagroup.net |
| លេខចុះបញ្ជីក្រុមហ៊ុន | ០០០០១១២១ ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០០២ |
| លេខចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | ០៦៨/២០ គ.ម.ក សសរ SECC ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០២០ |
| ឈ្មោះអ្នកតំណាងរបស់ក្រុមហ៊ុនបោះផ្សាយ | លោក ងន សាំង |
| លេខាធិការក្រុមហ៊ុន | លោក មាស សុវណ្ណ (អ៊ីមែល៖ sovan.meas@rmagroup.net) |

### ខ. សកម្មភាពអាជីវកម្ម

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនចែកចាយរថយន្ត គ្រឿងចក្រកសិកម្ម និងគ្រឿងបន្លាស់ធន់ធ្ងន់នៅក្នុងប្រទេសកម្ពុជា ហើយក៏ជាក្រុមហ៊ុនផ្តល់ការធានា និងសេវាកម្មក្រោយការលក់សម្រាប់ម៉ាកល្បីៗលំដាប់ពិភពលោករួមមានដូចជា Ford, Changan, Land Rover, ការចែកចាយ និង សេវាកម្មក្រោយការលក់ម៉ាក Jeep, សេវាកម្មក្រោយការលក់ម៉ាក RAM, សេវាកម្មក្រោយការលក់ម៉ាក Mercedes-Benz, John Deere, JCB, FUSO, AJAX, TCM, MS Pallet, Megger & Sebar, GenieGrips, Hako, PowerBoss, Piaggio, Haulotte, និង គ្រឿងបន្លាស់រថយន្ត (ថ្នាំលាបរថយន្ត និង អាគុយ)។

ប៉ុន្មានឆ្នាំកន្លងមកនេះ ក្រុមហ៊ុនទទួលបានកេរ្តិ៍ឈ្មោះជាក្រុមហ៊ុនផ្តល់សេវាកម្មនាំចូលរថយន្ត និង ផ្តល់ដំណោះស្រាយលើសេវាកម្មផ្សេងៗដែលទាក់ទងនឹងគ្រឿងផ្គត់ផ្គង់ និងសេវាថែទាំក្រោយការលក់។

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Clipper Holdings Limited ដែលជាក្រុមហ៊ុនមេរបស់ RMA Group ដែលមានទីស្នាក់ការកណ្តាលប្រតិបត្តិប្រចាំតំបន់នៅទីក្រុងបាងកក ប្រទេសថៃ។

## គ. ព្រឹត្តិការណ៍សំខាន់ៗក្នុងរយៈពេលនៃរបាយការណ៍ត្រីមាស

ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសត្រូវបានកំណត់ដូចខាងក្រោម៖

### ខែ តុលា ឆ្នាំ២០២៤

នៅថ្ងៃទី២៩ ខែតុលា RMAC ទទួលបានពាន រង្វាន់ក្នុងការបំពេញការងារឆ្នើម និងការយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍន៍ទីផ្សារមូលបត្រនៅ កម្ពុជា។ RMAC ទទួលបានពានរង្វាន់ដ៏មាន កិត្យានុភាពគឺ "បណ្ណសសើរការបង្ហាញព័ត៌មាន សាជីវកម្មឆ្នើមប្រចាំឆ្នាំ ២០២៤" និង "លិខិតថ្លែងអំណរគុណសម្រាប់ការចូលរួមយ៉ាងសកម្មក្នុងបុព្វហេតុវិស័យមូលបត្រ"។




### ខែ វិច្ឆិកា ឆ្នាំ២០២៤

នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤ RMAC និង Bendigo Kangan Institute (BKI) Group នៃប្រទេសអូស្ត្រាលី បានចុះអនុស្សរណៈ នៃការ យោគយល់ ដើម្បីបង្កើតមជ្ឈមណ្ឌលឧត្តមភាពយានយន្តនៅកម្ពុជា ក្រោមការសហការគាំទ្រ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។




### ខែ វិច្ឆិកា ឆ្នាំ២០២៤

នៅថ្ងៃទី ០៨ ខែវិច្ឆិកា RMAC បានបើកសម្ពោធជាផ្លូវការនូវអគារតាំងបង្ហាញថ្មី និងម៉ូដែលរថយន្ត ALL-New Jeep Wrangler Rubicon ។ ម៉ាករថយន្ត Jeep ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុន Stellantis Group ។



## ខែធ្នូ ឆ្នាំ២០២៤




នៅថ្ងៃទី១៦ ខែធ្នូ RMAC បានបើកសម្ពោធអគារ John Deere 3S ថ្មីរបស់ខ្លួននៅក្នុងខេត្តត្បូងឃ្មុំ។ កម្មវិធីនេះប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម ប៉ែន កុសល្យ អភិបាលនៃ គណៈអភិបាលខេត្ត និងលោក ងន សាំង នាយកប្រតិបត្តិ RMAC ។

## ខែធ្នូ ឆ្នាំ២០២៤

នៅក្នុងខែធ្នូ RMAC ជាក្រុមហ៊ុនដែលទទួលបានសិទ្ធិចែកចាយពីផលិតផល John Deere បានសម្រេចនូវព្រឹត្តិការណ៍ដ៏សំខាន់មួយ ដោយទទួលបានរង្វាន់ដ៏មានកិត្យានុភាពពីរគឺ "JDA Outstanding Dealer Award" និង "A&CS High Performance Dealer Award" !




## ផ្នែកទី២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក. លទ្ធផលប្រតិបត្តិការធុរកិច្ច និង ព័ត៌មានធុរកិច្ចតាមផ្នែក

សរុបទីផ្សាររថយន្តថ្មីនៅកម្ពុជា ឆ្នាំ២០២៤ ត្រូវបានប៉ាន់ស្មានថាបានកើនឡើង +១៣% ធៀបនឹងឆ្នាំមុន ដែលមានចំនួនតិចជាង ២៧.០០០ គ្រឿង។

ក្នុងកំឡុងត្រីមាសទី៤ ការអនុវត្តរបស់ ក្រុមហ៊ុន RMAC នៅក្នុងផ្នែកសំខាន់ៗគឺៈ

**<u>ផ្សាររបស់រថយន្តម៉ាក Ford៖</u>**

រថយន្តម៉ាក Ford នៅតែរក្សាចំណាត់ថ្នាក់លេខមួយនៃរថយន្តដែលលក់ដាច់បំផុតនៅលើទីផ្សារនៃប្រទេសកម្ពុជា ក្នុងចំណោមទីផ្សាររថយន្តដែលមិនប្រណិត ជាមួយនឹងរថយន្តម៉ាក Ford Ranger ត្រូវបានជាប់ចំណាត់ថ្នាក់លេខមួយ ដែលលក់ដាច់បំផុតនៅលើទីផ្សារក្នុងប្រទេសកម្ពុជា។ យើងពិតជាមានមោទនភាពដែលរថយន្តដែលលក់បានភាគច្រើនត្រូវបានផលិតក្នុងប្រទេសកម្ពុជា។

**<u>គ្រឿងចក្រម៉ាក John Deere៖</u>** ដោយយោងតាមរបាយការណ៍ផ្ទៃក្នុងរបស់ក្រុមហ៊ុន គ្រឿងចក្រម៉ាក John Deere នៅជាអ្នកនាំមុខទី២ នៅក្នុងទីផ្សារត្រាក់ទ័រក្នុងប្រទេសកម្ពុជា និងរក្សាតំណែងជាអ្នកនាំមុខលើត្រាក់ទ័រធុនធំ និងម៉ាស៊ីនប្រមូលផលនៅកម្ពុជា ហើយបានដណ្តើមយកចំណាត់ថ្នាក់ទីផ្សារវិញក្នុងកំឡុងឆ្នាំ ២០២៤។

**<u>លទ្ធផលហិរញ្ញវត្ថុ៖</u>**

ដោយសារការស្ទុះងើបឡើងវិញនៃទីផ្សាររបស់រថយន្ត ព្រមទាំងទិដ្ឋភាពវិជ្ជមាននៃវិស័យកសិកម្ម ក្រុមហ៊ុន RMAC ទទួលបានប្រាក់ចំណូលចំនួន ៣៩៦ ប៊ីលានរៀល ដែលមានការកើនឡើងចំនួន +២៥,៦% បើប្រៀបធៀបនឹងឆ្នាំមុន។ សម្រាប់ដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៤ ប្រាក់ចំណេញក្រោយបង់ពន្ធមានចំនួន ១៤,១ ប៊ីលានរៀល ធ្លាក់ចុះ -១៣,១% ធៀបនឹងលទ្ធផលឆ្នាំមុន។

លំហូរសាច់ប្រាក់សុទ្ធដែលប្រើប្រាស់លើការវិនិយោគនូវសាច់ប្រាក់មានចំនួន ៣០១,៧ ប៊ីលានរៀល ក្នុងត្រីមាសទី៤ ឆ្នាំ២០២៤។ ទន្ទឹមនឹងនេះ សាច់ប្រាក់ចំនួន ១៥,១ ប៊ីលានរៀល ត្រូវបានធ្វើការវិនិយោគដោយជោគជ័យលើការសាងសង់លើអគារតាំងបង្ហាញ និងយានដ្ឋានជួសជុលជាដើម។

## ខ. វចនាសម្ព័ន្ធប្រាក់ចំណូល

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនដែលមានលក្ខណៈបែបចម្រុះ ដែលបានតំណាងអោយយីហោលំដាប់ពិភពលោកមួយចំនួនរួមមាន Ford, Land Rover, Changan, After-Sales Mercedes-Benz, Fuso, John Deere, JCB និង Piaggio។ ផលចំណូលរបស់ក្រុមហ៊ុនទាំងអស់ ត្រូវបានបែងចែកជាពីរប្រភេទ៖

១. ការលក់ទំនិញ៖ ចំណូលទាក់ទងនឹងការលក់យានយន្ត និងឧបករណ៍ផ្សេងៗ។

២. ចំណូលពីសេវាកម្ម៖ ចំណូលទាក់ទងនឹងសេវាជួសជុល និងថែទាំយានយន្ត និងឧបករណ៍។

តារាងខាងក្រោមបង្ហាញពីចំណូលពីរប្រភេទ (ទំនិញ ឬ យានយន្ត និង សេវាកម្មក្រោយការលក់) សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៤ និងរយៈពេលប្រៀបធៀបក្នុងកំឡុងពេលបីឆ្នាំចុងក្រោយ។

| គិតជាពាន់រៀល | ត្រីមាសទី៤ ឆ្នាំ២០២៤ | ភាគរយ | ត្រីមាសទី៤ ឆ្នាំ២០២៣ | ភាគរយ | ត្រីមាសទី៤ ឆ្នាំ២០២២ | ភាគរយ |
|---|---|---|---|---|---|---|
| **ការលក់ទំនិញ** | ៣៦៣.០៦៥.៩៧៣ | ៩១,៧% | ២៩៦.៧៥៥.២៩១ | ៩៤,១% | ៦៥២.០៦៩.០៨៣ | ៩៧,២% |
| **ចំណូលនៃសេវាកម្ម** | ៣៣.០០៧.៤៩៦ | ៨,៣% | ១៨.៤៩៥.០៥៥ | ៥,៩% | ១៨.៤៤៨.០០៩ | ២,៨% |
| **សរុប** | ៣៩៦.០៧៣.៤៦៩ | ១០០,០% | ៣១៥.២៥០.៣៤៦ | ១០០,០% | ៦៧០.៥១៧.០៩២ | ១០០,០% |

## ផ្នែកទី៣.- របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករ

សូមយោងទៅលើឧបសម្ព័ន្ធស្តីពីព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្នសម្រាប់បញ្ចប់ត្រីមាស គិតត្រឹម

ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។

## ផ្នែកទី៤. ការពិភាក្សា និង ការវិភាគរបស់គណៈគ្រប់គ្រង

### ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

#### ១. ការវិភាគចំណូល

ចំណូលសរុប មានចំនួន ៣៩៦,១ ប៊ីលានរៀល កើនឡើងចំនួន ៨០,៨ ប៊ីលានរៀល ឬ +២៥,៦% ភាគរយ នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៤ បើធៀបនឹងត្រីមាសដូចគ្នាក្នុងឆ្នាំ២០២៣។

#### ២. ផ្នែកនៃចំណូល

ផ្នែកដែលនាំមុខគេគឺ ផ្នែករថយន្ត ហ្វដ (Ford) និង ផ្នែកបរិក្ខាកសិកម្ម (Agricultural Equipment)។ ចំណែកឯរថយន្ត Changan កំពុងកើនឡើងនៃការលក់ ខណៈពេលដែល រថយន្ត Land Rover បានបង្ហាញពីការធ្លាក់ចុះបន្តិច។

#### ៣. ការវិភាគអំពីប្រាក់ចំណេញមុនបង់ពន្ធ (PBT)

| គិតជាពាន់រៀល | ត្រីមាសទី៤ ឆ្នាំ២០២៤ | ត្រីមាសទី៤ ឆ្នាំ២០២៣ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| ចំណូលសរុប | ៣៩៦.០៧៣.៤៦៩ | ៣១៥.២៥០.៣៤៦ | ៨០.៨២៣.១២៣ | ២៥,៦% |
| ចំណេញដុល | ៦៨.៦៦៩.១៣០ | ៤៩.៤៩៧.៨២៩ | ១៩.១៧១.៣០១ | ៣៨,៧% |
| គម្លាតចំណេញដុល | ១៧,៣% | ១៥,៧% | | |
| ចំណាយ | ៤៤.៥៤៦.៩១៤ | ៥៥.៨១៦.៦៧២ | (១១.២៦៩.៧៥៨) | -២០,២% |
| ចំណាយហិរញ្ញវត្ថុ | ៥.៥៤០.៥៧៦ | ៨.៦២២.៣៥៦ | (៣.០៨១.៧៨០) | -៣៥,៧% |
| ប្រាក់ចំណេញមុនបង់ពន្ធ | ២០.២៧៧.៨២៤ | (១៤.៩៤១.១៩៩) | ៣៥.២១៩.០២៣ | -២៣៥,៧% |
| គម្លាត | ៥,១% | -៤,៧% | | |

#### ៤. ការវិភាគអំពីប្រាក់ចំណេញក្រោយបង់ពន្ធ (PAT)

| គិតជាពាន់រៀល | ត្រីមាសទី៤ ឆ្នាំ២០២៤ | ត្រីមាសទី៤ ឆ្នាំ ២០២៣ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ២០.២៧៧.៨២៤ | (១៤.៩៤១.១៩៩) | ៣៥.២១៩.០២៣ | -២៣៥,៧% |
| ចំណាយពន្ធ | ៦.១២៧.៩៤៣ | ២៩.០៣០.៧៩៩ | (២២.៩០២.៨៥៦) | -៧៨,៩% |
| ប្រាក់ចំណេញក្រោយបង់ពន្ធ | ១៤.១៤៩.៨៨១ | (១៣.០៧៥.៩៥៣) | ២៧.២២៥.៣៣៤ | -២០៨,២% |
| គម្លាតប្រាក់ចំណេញក្រោយបង់ពន្ធ | ៣,៦% | -៤,១% | | |

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ

### ១. ការវិភាគអំពីតម្រូវការ និង ការផ្គត់ផ្គង់

ជាទូទៅអតិថិជនរបស់ RMAC នៅក្នុងប្រទេសកម្ពុជាបានបង្ហាញពីចំណាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការទិញផលិតផលសំខាន់ៗរបស់ RMAC ដែលមានដូច ជា Ford, Changan, John Deere និង Land Rover ។

បច្ចុប្បន្ន RMAC កំពុងតាមដានយ៉ាងជិតដល់នូវការនាំចូល និងប្រភពធនធាននៃផលិតផលសម្រាប់ផ្នែកនីមួយៗ ដើម្បីធ្វើការសម្រេចចិត្តសមស្របតាមលក្ខខណ្ឌនៃការបញ្ជាទិញផលិតផល។

### ២. ការវិភាគអំពីការប្រែប្រួលនូវតម្លៃវត្ថុធាតុដើម

មិនមានការប្រែប្រួលសំខាន់លើតម្លៃនៃវត្ថុធាតុដើមឡើយ។

### ៣. ការវិភាគអំពីពន្ធដារ

មិនមានការប្រែប្រួលលើលិខិតបទដ្ឋានគតិយុត្តិផ្នែកពន្ធដារក្នុងប្រទេសកម្ពុជាណាមួយ ដែលនាំអោយមានផលប៉ះពាល់សំខាន់ណាមួយដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

### ៤. ការវិភាគអំពីទំនិញលើកលែង និងទំនិញពិសេស

មិនមានទំនិញសំខាន់អ្វីដែលជាទីគួរឱ្យកត់សម្គាល់នៅក្នុងត្រីមាសនេះទេ។

## គ. ការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល

ចំណូលសម្រាប់ត្រីមាសទី៣ ឆ្នាំ២០២៤ ប្រៀបធៀបរយៈពេលដូចគ្នានាឆ្នាំ ២០២៣ ដែលត្រូវបានបង្ហាញក្នុងឯកសារនេះ និងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេប។

## ឃ. ផលប៉ះពាល់នៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ

ការប្រែប្រួលអត្រាប្តូរប្រាក់ មិនមានការប៉ះពាល់ចំបងណាមួយដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ ដោយហេតុថាអាជីវកម្មមួយចំនួនធំរបស់ក្រុមហ៊ុនត្រូវបានធ្វើឡើងជាប្រាក់រៀល/ប្រាក់ដុល្លារអាមេរិក ដោយភ្ជាប់ជាមួយនឹងការបញ្ជាទិញនូវផលិតផលនាំចូលតិចតួចប៉ុណ្ណោះដែលធ្វើឡើងជារូបិយបណ្ណបរទេស។ ក្រុមហ៊ុន មិនបានទទួលរងផលប៉ះពាល់ដោយតម្លៃទំនិញ ដោយសារក្រុមហ៊ុនមិនបានធ្វើការដោះដូរទំនិញឡើយ។ អត្រាការប្រាក់ មានការប្រែប្រួលបន្តិចបន្តួចតែប៉ុណ្ណោះក្នុងអំឡុងពេលនេះ។

## ង. ផលប៉ះពាល់នៃអតិផរណា

មិនមានផលប៉ះពាល់ចំបងណាមួយនៃអតិផរណា ដែលបានប៉ះពាល់ដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

នាពេលថ្មីៗនេះ យើងមិនត្រូវទទួលបានការជូនដំណឹងអំពីគោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ ឬ រូបិយវត្ថុដែលអាចមានផលប៉ះពាល់ដល់អាជីវកម្មរបស់ RMAC តាមរបៀបណាមួយឡើយ។

## ឆ. ព្រឹត្តិការណ៍សំខាន់ផ្សេងៗ

មិនមានព្រឹត្តិការណ៍សំខាន់ៗក្នុងត្រីមាសនេះទេ។

ហត្ថលេខារបស់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ

កាលបរិច្ឆេទ៖ ២១ កុម្ភៈ ២០២៥

| | |
|---|---|
| បានឯកភាព និង អនុម័ត | បានឯកភាព និង អនុម័ត |
| ឈ្មោះ Kevin Whitcraft | ឈ្មោះ ងន សាំង |
| តួនាទី៖ ប្រធានក្រុមប្រឹក្សាភិបាល | តួនាទី៖ នាយកប្រតិបត្តិ |

